# ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានជួបពិភាក្សាការងារជាមួយឯកឧត្តម Chan byoung Wan ប្រធានគណៈកម្មាធិការផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម ថាមពល សហគ្រាសធុនតូច និងមធ្យម និងវិនិយោគរបស់សាធារណរដ្ឋកូរ៉េ



កាលពីថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៧ នៅទីក្រុង សេអ៊ូល សាធារណរដ្ឋកូរ៉េ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានជួបពិភាក្សាការងារជាមួយឯកឧត្តម Chan byoung Wan ប្រធានគណៈកម្មាធិការផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម ថាមពល សហគ្រាសធុនតូច និងមធ្យម និងវិនិយោគរបស់សាធារណរដ្ឋកូរ៉េ ក្នុងន័យពង្រឹងចំណងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរបន្ថែមទៀត លវិស័យឧស្សាហកម្ម និងពាណិជ្ជកម្មរបស់កូរ៉េមកកម្ពុជាឲ្យបានទំហំ១ពាន់លានដុល្លារនាឆ្នាំខាងមុខ។



ឯកឧត្តមទេសរដ្ឋមន្ត្រី បានរំលឹកថា កន្លងមកការវិនិយោគរបស់កូរ៉េមកកម្ពុជា មានទំហំ ទឹកប្រាក់ ចំនួន ៦០០ លានដុល្លារអាមេរិក លើវិស័យផលិត សម្លៀកបំពាក់ និងតម្លើងរថយន្ត(Hyundai)។ ជាមួយគ្នានេះ ឯកឧត្តម បានស្នើឲ្យភាគីកូរ៉េចាប់អារម្មណ៍វិនិយោគ បន្ថែមទៀត ផ្នែកឧបករណ៍អេឡិចត្រូនិច និងបរិក្ខាអគ្គិសនី ជាដើម ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានលើកឡើងពី លក្ខណៈអំណោយផល និងឱកាសវិនិយោគដ៏ប្រសើរនៅកម្ពុជា ដោយកម្ពុជាមានសុខ សន្តិភាពពេញលេញ និងភាពអនុគ្រោះពាណិជ្ជកម្ម ដែលកម្ពុជាទទួលបានពីប្រទេសអភិវឌ្ឍ និងជាប្រទេសដៃគូជាច្រើន ដែលអនុញ្ញាតឲ្យទំនិញរាប់ពាន់មុខពីកម្ពុជា នាំចេញដោយរួចពន្ធ និងមិនជាប់កូតា រួមទាំងនាំចេញទៅប្រទេសកូរ៉េផងដែរ ។ ទន្ទឹមនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ក៏បានធ្វើការកត់សំគាល់ពីកំណើនទេសចរណ៍របស់ភ្ញៀវជនជាតិកូរ៉េមកកម្ពុជា មានកំណើនកើនឡើង ដែលឆ្នាំកន្លងទៅមានចំនួន ៤ សែននាក់ ដែលធ្វើឲ្យជើងហោះហើរដោយផ្ទាល់ពីកូរ៉េមកកម្ពុជា មានចំនួន៣៥ជើង ក្នុងមួយសប្តាហ៍ ។ ដោយឡែកពលករកម្ពុជាទៅធ្វើការ

នៅប្រទេសកូរ៉េ ប្រមាណជិត ៨ម៉ឺននាក់ឯកឧត្តមទេសរដ្ឋមន្ត្រី បានចាត់ទុកជាសក្តានុពលមួយ ពីព្រោះពួកគេ បានទទួលបទពិសោធន៍ ចំណេះដឹង និងការ អនុវត្តន៍ផ្ទាល់ នឹងក្លាយជាកំលាំងចូលរួមយ៉ាងសំខាន់ ក្រោយពួកគេត្រឡប់មកកម្ពុជាវិញ ដែលអាចចូលរួមបម្រើការងារនៅក្រុមហ៊ុន កូរ៉េ នៅកម្ពុជា នាពេលអនាគតបន្តបន្ទាប់។



ឯកឧត្តម Chan byoung Wan បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ ហើយកម្ពុជា-កូរ៉េ នឹងខិតខំពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការល្អនេះបន្ថែមទៀត និងមានច្រើនវិស័យដូចជា៖ថាមពលកកើតឡើងវិញ -ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ-កិច្ចសហការលើជំនាញបច្ចេកទេស-ការបង្កើតសួនឧស្សាហាកម្ម និងបច្ចេកវិទ្យា ជាពិសេសការអភិវឌ្ឍន៍វិស័យសហគ្រាសធុនតូច និងមធ្យម ដែលភាគីកូរ៉េចាត់ទុកជាអាទិភាព សម្រាប់គាំទ្រឧស្សាហាកម្ម ធន់ស្រាល និងធ្ងន់ និងជាសរសៃឈាមចូលរួមអភិវឌ្ឍ សេដ្ឋកិច្ចជាតិផងដែរ ។